**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# សារលិខិត

**របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**អបអរសាទរពិធីបុណ្យសមុទ្រលើកទី ៦ ក្រោមប្រធានបទ**

**"ឆ្នេរសមុទ្របៃតង៖ អនាគតគឺបច្ចុប្បន្ន" ក្រោមពាក្យស្លោក "និរន្តរភាពទេសចរណ៍សម្រាប់ការអភិវឌ្ឍ"**

(Green Bay: the Future is Now, Sustainable Tourism for Development)

**ខេត្តកែប. ថ្ងៃទី ២២-២៤ ខែ ធ្នូ ឆ្នាំ ២០១៧**

– *ជនរួមជាតិទាំងអស់ជាទីមេត្រី!*

ក្នុងរយៈពេលជាងមួយទសវត្សរ៍ចុងក្រោយនេះ កម្ពុជាបានឆ្លងកាត់នូវការផ្លាស់ប្តូរយ៉ាងច្រើនទាំងក្នុងទិដ្ឋភាពនយោបាយ សន្តិសុខ សេដ្ឋកិច្ច និងសង្គម។ កម្ពុជាផ្លាស់ប្តូររូបភាពយ៉ាងឆាប់រហ័សពីអ្វីដែលធ្លាប់ស្គាល់ថាជាទឹកដីនៃវាលពិឃាត សង្គ្រាម មកប្រទេសមានសុខសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សុវត្ថិភាពពេញលេញ មានការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ និងជាគោលដៅទេសចរណ៍លំដាប់ពិភពលោកប្រកបដោយក្តីសង្ឃឹមឆ្ពោះទៅរកអនាគតដ៏រុងរឿង និងត្រចះត្រចង់។

ក្នុងស្មារតីឆ្លើយតបទៅនឹងនិន្នាការអភិវឌ្ឍន៍នេះ រាជរដ្ឋាភិបាលបានចាត់ទុកវិស័យទេសចរណ៍ជាវិស័យអាទិភាពជា"**មាសបៃតង**" រួមចំណែកដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ តាមរយៈការបង្កើត និងបង្កើននូវឱកាសការងារ បង្កើនប្រាក់ចំណូលជូនប្រជាជនដោយផ្ទាល់ និងដោយប្រយោល ជំរុញការនាំចេញនៅនឹងកន្លែង ទ្រទ្រង់កំណើនសេដ្ឋកិច្ច បង្កើនចំណូលជាតិ ចូលរួមដល់ការអភិរក្សវប្បធម៌ និងថែរក្សាការពារបរិស្ថាន ធនធានធម្មជាតិរបស់យើងប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់។

ទន្ទឹមនឹងនេះ កាលពីឆ្នាំ២០១១ តំបន់ឆ្នេរសមុទ្រកម្ពុជាបានក្លាយជាសមាជិកក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក ដែលបាននិងកំពុងរួមចំណែកយ៉ាងសកម្មធ្វើអោយកម្ពុជាក្លាយទៅជាគោលដៅទេសចរណ៍ប្រកបដោយឧត្តមភាព និងភាពទាក់ទាញខ្ពស់ ចូលរួមចំណែកសម្រេចចក្ខុវិស័យអាស៊ានជាគោលដៅទេសចរណ៍លំដាប់ពិភពលោក និងប្រកបដោយភាពកក់ក្តៅ " ASEAN: The world class Destination" និង " ASEAN: Feel the warmth" ។ កិច្ចការនេះបានធ្វើឲ្យតំបន់ឆ្នេរសមុទ្រកម្ពុជាបាននឹងកំពុងបានដើរតួនាទីយ៉ាងសំខាន់ជាប៉ូលសេដ្ឋកិច្ចក្នុងការទាក់ទាញការវិនិយោគសម្រាប់ជំរុញកំណើនសេដ្ឋកិច្ច និងត្រូវបានចាត់ទុកជាគោលដៅទេសចរណ៍ដ៏មានភាពទាក់ទាញ និងប្រកបដោយភាពប្រកួតប្រជែងខ្ពស់នៅកម្ពុជា និងក្នុងតំបន់។

ក្នុងបរិបទនេះ រាជរដ្ឋាភិបាលបានកំណត់ប្រារព្ធ **ពិធីបុណ្យសមុទ្រ** ដែលមិនត្រឹមតែរួមចំណែកក្នុងការផ្សព្វផ្សាយពីសក្តានុពលទេសចរណ៍នៃខេត្តតំបន់ឆ្នេរសមុទ្រប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចូលរួមគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការយកចិត្តទុកដាក់អភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវដោយឈរលើការប្តេជ្ញាចិត្តរួមមួយច្បាស់លាស់ក្នុងការរក្សាតុល្យភាពរវាងផលប្រយោជន៍សេដ្ឋកិច្ចសង្គម បរិស្ថាន និងវប្បធម៌ប្រជាពលរដ្ឋទាំងបច្ចុប្បន្ន និងអនាគត ដូចដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈប្រធានបទនៃបុណ្យសមុទ្រលើកទី៦នេះគឺ **"ឆ្នេរសមុទ្របៃតង៖ អនាគតគឺបច្ចុប្បន្ន"** ក្រោមពាក្យស្លោក **"និរន្តរភាពទេសចរណ៍សម្រាប់ការអភិវឌ្ឍ"** ។ ជាការពិត សក្តានុពលធនធានធម្មជាតិនៅតំបន់ឆ្នេរសមុទ្រកម្ពុជាដែលត្រូវបានប្រសិទ្ធនាមថា **"តារារះនាទិសនិរតី"** (The Rising Star of the Southwest) គឺមានលក្ខណៈលេចធ្លោមានភាពសំបូរបែប ដែលអំណោយផលដល់ការអភិវឌ្ឍទេសចរណ៍នៅក្នុងតំបន់នេះ។ ជាក់ស្តែង តំបន់ឆ្នេរសមុទ្រកម្ពុជាទទួលភ្ញៀវទេសចរអន្តរជាតិប្រមាណជាង**១៥%** នៃចំនួនទេសចរសរុបមកកម្ពុជា ហើយដែលចំណែកទីផ្សារបាននិងកំពុងកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ។ ការរីកចម្រើនទាំងនេះក៏មិនអាចកាត់ផ្តាច់ចេញពីកត្តាសន្តិសុខ ពោលគឺបានសបញ្ជាក់ឲ្យឃើញកាន់តែច្បាស់ថែមទៀតថា កម្ពុជាមានសុខសន្តិភាព ស្ថិរភាពនយោបាយសុខសុវត្ថិភាពពេញលេញ ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ល្អប្រសើរ ហើយស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចក៏មានលំនឹងល្អ។

ឈរលើមូលដ្ឋាននៃកំណើននេះ ការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជាមិនមែនធ្វើឡើងសម្រាប់តែពេលបច្ចុប្បន្ននោះទេ ប៉ុន្តែយើងត្រូវគិតគូឲ្យបានវែងឆ្ងាយទៅដល់អនាគត ដោយត្រូវមានផែនការច្បាស់លាស់ និងគ្រប់គ្រងភ្ញៀវទេសចរឲ្យបានម៉ត់ចត់ ពិសេសស្របពេលដែលពិភពលោកទាំងមូលបាននិងកំពុងប្រឈមនឹងការវិវត្តថ្មីៗឥតឈប់ឈរ ទាំងលើសេដ្ឋកិច្ច សង្គម និងបរិស្ថាន ដែលស្តែងឡើងតាមរយៈការប្រែប្រួលជាច្រើន ដូចជាភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចពិភពលោក បញ្ហាគ្រោះធម្មជាតិកើតឡើងជាបន្តបន្ទាប់ ការប្រែប្រួលអាកាសធាតុ និងការកើនឡើងកម្ពស់ទឹកសមុទ្រជាដើម។ ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមទាំងនេះ ការយកចិត្តទុកដាក់ដល់ទស្សនទាននៃភាពស្អាត និងបៃតង គឺពិតជាមានភាពចាំបាច់ ខណៈពេលដែលពិភពលោកទាំងមូលកំពុងបោះជំហានទៅមុខនៅក្នុងសម័យកាលបៃតង។ ផ្អែកលើទស្សនាទាននេះការអភិវឌ្ឍទេសចរណ៍តំបន់ឆ្នេរ ទាមទារចាំបាច់ឲ្យមានការ**អភិវឌ្ឍទីក្រុងស្អាត/ទីក្រុងបៃតង ឆ្នេរសមុទ្របៃតង និងកោះបៃតង** ស្របតាម**សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីគោលការណ៍ណែនាំអភិវឌ្ឍន៍រមណីយដ្ឋានឆ្នេរសមុទ្រ** ដែលជាគំរូអភិវឌ្ឍគិតគូរដល់ការអភិរក្ស ថែរក្សាសម្បត្តិវប្បធម៌ ធនធានធម្មជាតិ និងបរិស្ថានប្រកបដោយនិរន្តរភាព ពោលគឺ **អភិវឌ្ឍ ដើម្បីអភិរក្ស** ដោយត្រូវធានាឲ្យបាននូវនិរន្តរភាព និងតុល្យភាពផ្នែកសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន។

ក្នុងន័យនេះ យើងចាំបាច់ត្រូវរួមគ្នា **"រួមគិត រួមធ្វើ រួមទទួលខុសត្រូវ"** ក្នុងការអភិវឌ្ឍវិស័យទេសចរណ៍តំបន់ឆ្នេរកម្ពុជាឲ្យមាននិរន្តរភាព ហើយឆ្នេរសមុទ្រកម្ពុជាត្រូវតែជាឆ្នេរសមុទ្របៃតងដែលស័ក្តិសមជាសមាជិកក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក និងរួមចំណែកទប់ស្កាត់ការកើនឡើងនៃកំដៅផែនដីមិនឲ្យលើសពី ២អង្សាសេ ក្នុងសតវត្សទី២១ នេះ។

ឆ្លៀតឱកាសពិធីវិសេសវិសាលនេះ ខ្ញុំសូមអំពាវនាវដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ បងប្អូនជនរួមជាតិទាំងអស់ វិស័យឯកជន ចូលរួមឲ្យបានផុសផុលប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ធ្វើឲ្យពិធីបុណ្យសមុទ្រនៅឆ្នាំនេះប្រកបដោយភាពជោគជ័យ។ លើសពីនេះទៀត ខ្ញុំសូម

អំពាវនាវដល់ប្រតិបត្តិករទេសចរណ៍ ទេសចរជាតិ និងអន្តរជាតិ អាជ្ញាធរមូលដ្ឋាន និងបងប្អូនប្រជាពលរដ្ឋចូលរួមឲ្យកាន់តែសកម្មក្នុងចលនាប្រឡងប្រណាំង **"ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ"** និងសហការថែរក្សា សោភ័ណភាព អនាម័យ បរិស្ថាន ដែលជាកត្តាចម្បង ដែលមិនអាចខ្វះបានក្នុងការថែរក្សាតំបន់ឆ្នេរសមុទ្រឲ្យស្រស់ស្អាតយូរអង្វែង ដើម្បីបន្តជាមរតកដល់កូនចៅជំនាន់ក្រោយ។

ក្នុងន័យទាំងអស់នេះ ខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថា ការប្រារព្ធពិធីបុណ្យសមុទ្រនឹងជាកាល្លានុវត្តភាពដ៏ប្រសើរថ្មីមួយសម្រាប់កម្ពុជា ក្នុងការធ្វើឲ្យឆ្នេរសមុទ្រកម្ពុជាក្លាយជាគោលដៅទេសចរណ៍ប្រកបដោយគុណភាព ដែលជាកត្តាចូលរួមចំណែកក្នុងការផ្ដល់ការបង្កើនការងារ ការចូលរួមកាត់បន្ថយភាពក្រីក្រ និងការការពារបរិស្ថានធនធានធម្មជាតិជូនដល់ប្រជាពលរដ្ឋក្នុងតំបន់ឆ្នេរ ពិសេសចូលរួមចំណែកធ្វើឲ្យសម្រេចបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ របស់អង្គការសហប្រជាជាតិ ព្រមទាំងបង្កើនស្មារតីស្រឡាញ់ជាតិ មាតុភូមិ សាមគ្គីភាព និងមិត្តភាពផងដែរ។ ចំពោះមុខនេះ ខ្ញុំក៏សូមជូនពរឲ្យ**ការប្រារព្ធពិធីបុណ្យសមុទ្រ** នាឆ្នាំ២០១៧នេះ ប្រព្រឹត្តទៅយ៉ាងអធិកអធម និងប្រកបដោយភាពសប្បាយរីករាយ៕

រាជធានីភ្នំពេញ. ថ្ងៃទី ០៤ ខែ [illegible] ឆ្នាំ ២០១៧

**ហ៊ុន សែន**